ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ៥៩០៧ស៤៧·អក·សរក


# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោក លោកស្រីដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជា ជ្រាបថា៖ កាលពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១២ : ៥៨នាទី មានការដាច់ចរន្តលត់ទាំងស្រុងនៅតាមបណ្តាអនុស្ថានីយមួយចំនួនក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះរួមមាន អនុស្ថានីយទី១ ដែលមានទីតាំងនៅទួលសង្កែ, អនុស្ថានីយទី៣ ដែលមានទីតាំងនៅអូរបែកក្អម អនុស្ថានីយទី៥ មានទីតាំងនៅសង្កាត់ក្រាំងធ្នង់ និងអនុស្ថានីយកំពង់ស្ពឺ ស្ថិតនៅខេត្តកំពង់ស្ពឺ។ ការដាច់ចរន្តនៃការផ្គត់ផ្គង់នេះបណ្តាលមកពីមានរថយន្តបើកទាក់ខ្សែInternet ហើយដាច់វាត់ប៉ះខ្សែបណ្តាញ តង់ស្យុងខ្ពស់ 115 kV ចន្លោះពីអនុស្ថានីយទី៤ ទៅអនុស្ថានីយទី១ តាមជងផ្លូវហាណូយ។ ហេតុការណ៍នេះបណ្តាលអោយមានការដាច់ចរន្តស្ទើរតែពាក់កណ្តាលរាជធានីភ្នំពេញ និងទីរួមខេត្តកំពង់ស្ពឺ។ កន្លងមកឧបទ្ទវហេតុដែលបណ្តាលអោយដាច់ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយផ្នែក ឬរលត់ទាំងស្រុងរួមមាន៖ ការឆ្លងចរន្តដោយសារតែកម្មករសំណង់លើកដែកធ្វើអោយប៉ះ ឬបោះខ្សែភ្លើងឆ្លងកាត់ ឬ រថយន្តស្ទូច រថយន្តចាក់បេតុង ធ្វើអោយប៉ះ ឬមានការសាងសង់សំណង់នៅកៀកខ្សែបណ្តាញតង់ស្យុងខ្ពស់ហើយធ្វើអោយប៉ះខ្សែបណ្តាញតង់ស្យុងខ្ពង់ជាដើម។

ដើម្បីបង្ការកុំអោយមានឧបទ្ទវហេតុដូចខាងលើ **អគ្គិសនីកម្ពុជា** សូមសំណូមពរ អោយបងប្អូនប្រជាពលរដ្ឋមេត្តាប្រុងប្រយ័ត្ន ក្នុងការសាងសង់សំណង់ផ្សេងៗក្បែរគន្លងខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ មេត្តាសហការជាមួយ **អគ្គិសនីកម្ពុជា** ដើម្បីជៀសវាងកុំអោយមានគ្រោះថ្នាក់ដល់ជីវិត ក៏ដូចជាមានការដាច់ចរន្តលត់ដល់រាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន។ ម្យ៉ាងទៀតអគ្គិសនីកម្ពុជាសំណូមពរដល់ក្រុមហ៊ុនធ្វើអាជីវកម្ម ខ្សែ Internet ខ្សែទូរស័ព្ទ ទូរទស្សន៍ខ្សែកាប សូមមេត្តាប្រញ៉ាប់ ដោះចេញខ្សែដែលបំពាក់លើបង្គោលអគ្គិសនីតង់ស្យុងខ្ពស់របស់**អគ្គិសនីកម្ពុជា**។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤

**ជ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**ងិន_អ៊ុង**